ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**
-សំណុំរឿងរដ្ឋប្បវេណីលេខៈ ៩៧
ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០
-សាលក្រមលេខៈ ០២ "ជ"
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

# សាលក្រម
## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខៈ ៩៧ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើមចោទឈ្មោះ** [redacted] ប៊ុនហួញ ភេទប្រុស អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**ចុងចម្លើយឈ្មោះ** [redacted] គួន អាយុ៣៩ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] នីវ៉ា អាយុ២៩ឆ្នាំ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.បង្គាប់ឱ្យចុងចម្លើយរុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងរបស់ខ្លួនលើក្បាលដីលេខៈ ៣២៥ មានទីតាំងស្ថិតនៅភូមិពេជចង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ។

២.បង្គាប់ឱ្យចុងចម្លើយសងការខូចខាតលើសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ២០ លានរៀល។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] ប៊ុនហួញ បានដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងខេត្តតាកែវ ដោយប្តឹងទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] គួន អាយុ៣៩ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] នីវ៉ា ធ្វើការរុះរើកែសម្រួលបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងរបស់ចុងចម្លើយលើក្បាលដីលេខៈ ៣២៥ មានទីតាំងស្ថិតនៅភូមិពេជចង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុក



Scanned with CamScanner

សំរោង ខេត្តតាកែវ វិញ ដោយដើមចោបានអះអាងថា: ចុងចម្លើយបានធ្វើបង្អួចបើកចេញមកខាងក្រៅលយចូលព្រំដីរបស់ខ្លួនដែលនៅជាប់គ្នា ហើយមានភាពផ្ទុយទៅនឹងលិខិតអនុញ្ញាតឱ្យសាងសង់ ខុសបទដ្ឋានបច្ចេកទេស និងបណ្តាលឱ្យប៉ះពាល់ដល់ការរស់នៅរបស់ដើមចោទដូចជាទឹកហូរធ្លាក់មកលើដីរបស់ដើមចោទ។ រឿងហេតុទាំងអស់នេះហើយបានជាដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងចូលមកសាលាដំបូងខេត្តតាកែវដើម្បីតែម្តង។

**គ. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**គ.១. ចំណុចវិវាទ :**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការកំណត់បានចំណុចវិវាទនៃរឿងក្តីមានដូចតទៅ:

-ចុងចម្លើមិនឯកភាពនឹងការទាមទាររបស់ដើមចោទថា:

១.បង្គាប់ឱ្យចុងចម្លើយរុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងលើក្បាលដីលេខ: ៣២៥ មានទីតាំងស្ថិតនៅភូមិពេជសង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ។

២.បង្គាប់ឱ្យចុងចម្លើយសងការខូចខាតលើសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ២០លានរៀល។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**គ.២. ចំណុចគ្មានវិវាទ:**

តាមរយៈការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការកំណត់បានចំណុចគ្មានវិវាទនៃរឿងក្តីមានដូចតទៅ:

-គ្មាន។

**ឃ. សេចក្តីថ្លែងការណ៍របស់គូភាគី**

**ឃ.១. សេចក្តីថ្លែងការណ៍របស់ដើមចោទ**

ដើមចោទឈ្មោះ [redacted] ប៊ុនហួញ ដោយមានលោក [redacted]: ជាមេធាវីតំណាងដោយអាណត្តិបានធ្វើសេចក្តីថ្លែងកាណ៍ថា: ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនៅតែរក្សាការទាមទារដូចមានក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទុកដដែល ដោយសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] គួន និងឈ្មោះ [redacted] នីវ៉ា រុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងលើក្បាលដីលេខ: ៣២៥ មានទីតាំងស្ថិតនៅភូមិពេជចង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ចេញវិញ ដោយហេតុថាឈ្មោះ [redacted] គួន និងប្រពន្ធរបស់គេឈ្មោះ [redacted] នីវ៉ា បានសាងសង់ផ្ទះរបស់គេតាំងពីអំឡុងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ដោយផ្ទះនោះមានកម្ពស់ ២ជាន់កន្លះ ហើយជាន់ផ្ទាល់ដីរបស់គេបានធ្វើបង្អួចបើកលយចេញមកខាងក្រៅ និងបានបើកបង្អួចនៃជាន់ផ្ទាល់ដីនោះគឺទើសទៅនឹងរបងផ្ទះរបស់កូនក្តីខ្លួន ហើយកូនក្តីខ្លួនក៏ពុំមានជំទាស់អ្វីនោះដែរ ប៉ុន្តែនៅជាន់ខាងលើនៃផ្ទះរបស់ចុងចម្លើយវិញគឺបានធ្វើបង្អួចលៀនចេញមកក្រៅដូចជាន់ផ្ទាល់ដីដែរ នៅពេលឈ្មោះ [redacted] គួន បានបើកបង្អួចផ្ទះ និងនៅពេលមានភ្លៀងធ្លាក់មកម្តងៗ គឺហូរទឹកធ្លាក់មកលើផ្ទះរបស់កូនក្តីខ្លួនជាប្រចាំតែម្តង។ ចំពោះការសាងសង់ផ្ទះរបស់ឈ្មោះ [redacted] គួន និងឈ្មោះ [redacted] នីវ៉ា នេះគឺមានការខុសទៅនឹងលិខិតអនុញ្ញាតឱ្យសាងសង់របស់ប្លង់ស្ថាបត្យកម្ម ដែលចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម

សំណង់ និងសុរិយោដីខេត្តតាកែវ។ ចំពោះប្លង់ស្ថាបត្យកម្មដែលបានចេញដោយប្រធានមន្ទីរសុរិយោដីខេត្តតាកែវ បញ្ជាក់ថាបង្អួចផ្ទះរបស់ចុងចម្លើយគឺធ្វើឡើងដោយការរអូសទៅចំហៀង មិនមែនជាប្រភេទបង្អួចដែលរុញចេញទៅក្រៅនោះទេ ហើយអាជ្ញាធរបានឱ្យចុងចម្លើយធ្វើការកែតម្រូវឱ្យត្រូវតាមប្លង់ស្ថាបត្យកម្ម និងបានឱ្យផ្អាកការសាងសង់រង់ចាំការដោះស្រាយដែរ ប៉ុន្តែចុងចម្លើយនៅតែបន្តការសាងសង់រហូតដល់រួចរាល់ជាស្ថាពរ។ មួយចំណែកទៀតចំពោះការបាញ់វីសឱ្យជាប់ទៅនឹងបង្អួចដើម្បីកុំឱ្យបើករុញចេញមកខាងក្រៅបាន គឺភាគីចុងចម្លើយបានធ្វើការបាញ់ដើម្បីបំភាន់ភ្នែកតុលាការនៅពេលដែលតុលាការចុះទៅពិនិត្យជាក់ស្តែងតែប៉ុណ្ណោះ ដោយកាលពីពេលមុនដែលតុលាការចុះទៅគឺមានការបើកលយចូលមកលើដីរបស់កូនក្តីខ្លួនពិតមែន។ ចំពោះចំណុចទី២.ទាក់ទងនឹងការទាមទារសងការខូចខាតលើសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ២០ លានរៀល ដោយសារតែកូនក្តីខ្លួនបានពឹងពាក់មេធាវីដើម្បីព្រឹក្សាផ្នែកច្បាប់ និងចាត់ចែងការងារលើកិច្ចការដាក់ពាក្យបណ្តឹងមកតុលាការមួយចំនួន និងមួយទៀត កូនក្តីខ្លួនបានចំណាយពេលវេលាច្រើនក្នុងការឡើងចុះដោះស្រាយបញ្ហាមួយនេះ។ ហេតុដូច្នេះហើយទើបបានជាកូនក្តីខ្លួនសុំទាមទារសងការខូចខាតលើសេវាកម្មច្បាប់ និងជម្ងឺចិត្តចំនួន ២០លានរៀល ។ ទី៣.ទាក់ទងនឹងប្រាក់ប្រដាប់ក្តីវិញកូនក្តីខ្លួនសុំចុងចម្លើយទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីដោយសារតែខាងកូនក្តីខ្លួនបានបង់ពន្ធដាក់ពាក្យបណ្តឹង និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធផ្សេងទៀតដើម្បីដំណើរការរឿងក្តី ដូច្នេះហើយទើបខាងកូនក្តីខ្លួនសុំឲ្យភាគីចុងចម្លើយជាអ្នកទទួលបន្ទុក ។ ហេតុដូច្នេះនាពេលនេះខ្លួនសំណូមពរសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយធ្វើការរុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃទីតាំងខាងលើចេញវិញដោយក្តីអនុគ្រោះ។

ឃ.២. សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

សហចុងចម្លើយឈ្មោះ [redacted] គួន និងប្រពន្ធឈ្មោះ [redacted] នីរ៉ា ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិបានធ្វើសេចក្តីថ្លែងកាណ៍ថា: ទាក់ទងនឹងការដាក់ពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] ប៊ុនហួញ ដោយសុំឲ្យតុលាការបង្គាប់កូនក្តីខ្លួនរុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងលើក្បាលដីលេខ: ៣២៥ មានទីតាំងស្ថិតនៅភូមិពេជចង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ គឺកូនក្តីខ្លួនពុំព្រមរុះរើបង្អួចចេញតាមការទាមទាររបស់ដើមចោទនោះទេ ដោយហេតុថា: កូនក្តីខ្លួនបានធ្វើត្រឹមត្រូវទៅនឹងលិខិតអនុញ្ញាតឱ្យសាងសង់របស់ប្លង់ស្ថាបត្យកម្មដែលចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ ហើយចំពោះបង្អួចនោះទៀតសោត គឺកូនក្តីខ្លួនពុំបានធ្វើលយចូលទៅក្នុងដីរបស់ដើមចោទនោះទេ។ ខ្លួនសូមបញ្ជាក់ថា:ចំពោះកំណត់ហេតុដែលមានការចុះសម្របសម្រួលពីសំណាក់ជាជ្ញាធរស្រុកកន្លងមកនោះ គឺគ្រាន់តែបានធ្វើការសម្រុះសម្រួលឱ្យភាគីមានការផ្សះផ្សារ និងសម្រុះសម្រួលគ្នាដើម្បីឱ្យត្រូវគ្នា និងយោគយល់គ្នាតែប៉ុណ្ណោះ ដោយពុំបានសម្រេច ថា: ភាគីខាងណាមានការខុស ឬត្រូវនោះទេ ហើយមួយចំណែកទៀតចំពោះប្លង់ស្ថាបត្យកម្ម ដែលចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវនោះ គឺពុំមានបញ្ជាក់ថាបង្អួចនោះធ្វើឡើងដោយទម្រង់ណាមួយនោះដែរ និងពុំបានបញ្ជាក់ថាជាបង្អួចប្រភេទរុញ ឬក៏ទាញនោះដែរ។ ហេតុដូច្នេះនាពេលនេះក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយខ្លួនសុំឱ្យតុលាការច្រានចោលនូវការទាមទាររបស់ដើមចោទចោលទាំងស្រុង។



Scanned with CamScanner

# សំអាងហេតុ

១.តាមពាក្យបណ្ដឹងចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] ប៊ុនហួញ ឃើញថាធ្វើឡើងត្រឹមត្រូវស្របតាមទម្រង់ដែលមានចែងនៅក្នុងបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម៉្យាងទៀតឃើញថាលំនៅឋានរបស់ដើមចោ និងចុងចម្លើយមានទីតាំងស្ថិតនៅក្នុងខេត្តតាកែវ នាំឲ្យសាលាដំបូងខេត្តតាកែវអាចយករឿងនោះមកដោះស្រាយបានស្របតាមបញ្ញត្តិមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ ឃើញថាកូនក្ដីរបស់ខ្លួនដាក់ពាក្យបណ្ដឹងសុំឲ្យតុលាការបង្គាប់ឲ្យភាគីចុងចម្លើយរុះរើបង្អួចផ្នែកខាងត្បូង និងផ្នែកខាងជើងនៃសំណង់ផ្ទះល្វែងលើក្បាលដីលេខ: ៣២៥ មានទីតាំងស្ថិតនៅភូមិពេជចង្វា ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ដោយសំអាងថា ភាគីខាងចុងចម្លើយបានធ្វើបង្អួចបើកចេញមកខាងក្រៅលយចូលព្រំដីរបស់កូនក្ដីខ្លួនដែលនៅជាប់គ្នា ហើយនៅពេលមានភ្លៀងធ្លាក់ម្ដងៗ គឺមានទឹកហូរធ្លាក់មកលើផ្ទះរបស់កូនក្ដីខ្លួនជាប្រចាំតែម្ដង ហើយការបាញ់វីសទៅលើបង្អួចទាំងអស់នោះ គឺគ្រាន់តែបំភាន់ភ្នែកតុលាការនៅពេលដែលតុលាការចុះពិនិត្យតែប៉ុណ្ណោះ ។ មួយវិញទៀតការសាងសង់នោះទៀតសោត គឺខុសទៅនឹងលិខិតអនុញ្ញាតឲ្យសាងសង់របស់ប្លង់ស្ថាបត្យកម្ម ដែលចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ ហើយអាជ្ញាធរក៏បានឲ្យភាគីខាងចុងចម្លើយធ្វើការកែតម្រូវឲ្យត្រូវតាម ប្លង់ស្ថាបត្យកម្ម និងបានឲ្យផ្អាកការសាងសង់រង់ចាំការដោះស្រាយគ្នាសិនផងដែរ ក៏ប៉ុន្តែភាគីចុងចម្លើយនៅតែបន្តការសាងសង់រហូតរួចរាល់ជាស្ថាពរ ។

៣.ផ្អែកតាមកំណត់ហេតុចុះពិនិត្យទៅលើទីតាំងវិវាទជាក់ស្ដែង ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ឃើញថាចំពោះបង្អួចដែលនៅលើផ្ទះរបស់ភាគីចុងចម្លើយ ហើយជាចំណុចវិវាទនៃរឿងក្ដី ឃើញថាបង្អួច នោះ គឺជាប្រភេទបង្អួចបើករុញចេញទៅក្រៅ ពីក្រោមឡើងលើ ដូចការលើកឡើងរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទពិតប្រាកដមែន ក៏ប៉ុន្តែឃើញថារាល់បង្អួចនីមួយៗត្រូវបានភាគីចុងចម្លើយដែលជាម្ចាស់បានប្រើប្រាស់វីសបាញ់ទៅលើបង្អួចនីមួយៗដើម្បីទប់បង្អួចនោះកុំឲ្យលយចូលទៅក្នុងដីរបស់ភាគីដើមចោទនៅពេលដែលបើកបង្អួចនោះ។ ក្នុងករណីនេះតុលាការយល់ឃើញថាការបាញ់វីសដើម្បីទប់ទៅលើបង្អួចនោះ គឺជាការត្រឹមត្រូវ ហើយក៏បញ្ចៀសនូវការធ្វើឲ្យប៉ះពាល់ផ្សេងៗទៅដល់ភាគីខាងដើមចោទផងដែរ។

៤.ផ្អែកតាមប្លង់ស្ថាបត្យកម្ម នៃគំរោងស្នើសុំសាងសង់ផ្ទះល្វែងអំពីបេតុងសសៃដែក មានជាន់ផ្ទាល់ដី ឡៅតឿ ជាន់ទី១ ជាន់ទី២ និងជាន់ទី៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលចេញដោយប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តតាកែវ ឃើញថាពុំមានចំណុចណាមួយបញ្ជាក់ថាបង្អួចដែលត្រូវសាងសង់នោះជាប្រភេទបង្អួចណាមួយឲ្យបានច្បាស់លាស់នោះទេ ពោលគឺគ្រាន់តែមានការគូសវាសបញ្ជាក់ថាចំណុចត្រង់ណាជាបង្អួចតែប៉ុណ្ណោះ ។

៥.ផ្អែកតាមសេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទដែលបានអះអាងថា: ក្នុងករណីសាងសង់បង្អួចនោះ អាជ្ញាធរក៏បានឲ្យភាគីចុងចម្លើយធ្វើការកែសម្រួលបង្អួចនោះឡើងវិញ ឲ្យត្រូវតាមប្លង់ស្ថាបត្យកម្ម ដែលនេះបញ្ជាក់ឲ្យឃើញថាការសាងសង់បង្អួចនោះពិតជាខុសនឹងប្លង់ស្ថាបត្យកម្មហើយ ។ ក្នុងករណីនេះ បើតាមការពិនិត្យទៅលើកំណត់ហេតុចុះថ្ងៃទី១១ ខែវិច្ឆិកា



Scanned with CamScanner

ឆ្នាំ២០១៧ ឃើញថាគ្រាន់តែជាកំណត់ហេតុមួយដែលអាជ្ញាធរចុះធ្វើការសម្របសម្រួលភាគីទាំងសងខាងតែប៉ុណ្ណោះ ហើយមិនមែនជាឯកសារបញ្ជាក់ថាតើបង្អួចដែលត្រូវសាងសង់នៅផ្ទះរបស់ចុងចម្លើយនោះជាបង្អួចប្រភេទអ្វីនោះដែរ។

៦.យល់ឃើញថាការសាងសងបង្អួចរបស់ភាគីចុងចម្លើយនៅលើផ្ទះរបស់ខ្លួន មិនបានសាងសង់ខុសទៅនឹងប្លង់ស្ថាបត្យកម្មនោះទេ ដោយសារតែនៅក្នុងប្លង់នោះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថាជាប្រភេទបង្អួចអ្វីឲ្យច្បាស់លាស់។ ម្យ៉ាងទៀតបើទោះជាការសាងសង់បង្អួចរបស់ភាគីចុងចម្លើយបានធ្វើលយចូលទៅក្នុងដីរបស់ភាគីដើមចោទ នៅពេលភាគីចុងចម្លើយបើកបង្អួចនោះក៏ដោយ តែឃើញថាភាគីចុងចម្លើយបានសម្រួលមិនបង្អួចនោះលយចូលទៅក្នុងដីរបស់ភាគីដើមចោទទៀតទេ នៅពេលខ្លួនបើបង្អួចនោះ តាមរយៈការយកវីសទៅបាញ់ភ្ជាប់នឹងបង្អួចទប់មិនឲ្យបង្អួចនោះបើកលយចូលទៅក្នុងដីរបស់ភាគីដើមចោទ។ ក្នុងករណីនេះ តុលាការយល់ឃើញថាភាគីដើមចោទមិនមានមូលហេតុក្នុងការប្តឹងទាមទារឲ្យចុងចម្លើយធ្វើការរុះរើបង្អួចដែលបានសាងសង់នៅលើផ្ទះរបស់ចុងចម្លើយនោះទេ គប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ។

៧.យល់ឃើញថាប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី តាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១.ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] ប៊ុនហួញ ភេទប្រុស អាយុ៥០ឆ្នាំ តាមពាក្យបណ្តឹងចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ ៩៧ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តតាកែវ ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះបានទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ និងប្រកាសនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ចំពោះមុខដើមចោទ និងចុងចម្លើយ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

តាកែវ, ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ចៅក្រម**

[redacted]



Scanned with CamScanner